**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ..........០៩៧/២១..........ក.ប/ស.ស.រ.ជក

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.កប ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញសេចក្តីសម្រេចលេខ ៦៦ សសរ ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ ស្តីពីការបង្កើតក្រុមការងារដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១. | **ឯកឧត្តម អ៊ិត សំហេង** | រដ្ឋមន្ត្រី នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២. | **ឯកឧត្តម ញឹក វណ្ណារ៉ា** | រដ្ឋលេខាធិការ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៣. | **លោកជំទាវ ជូ ប៊ុនអេង** | រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤. | **លោកជំទាវ ហ៊ូ សាមិត្ត** | រដ្ឋលេខាធិការ នៃក្រសួងកិច្ចការនារី | អនុប្រធាន |
| ៥. | **ឯកឧត្តម ស៊ា កុសល** | រដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៦. | **ឯកឧត្តម ហេង សួរ** | រដ្ឋលេខាធិការ នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៧. | **ឯកឧត្តម ហ៊ូ វុឌ្ឍី** | រដ្ឋលេខាធិការ នៃក្រសួងការងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធានអចិន្ត្រៃយ៍ |
| ៨. | **ឯកឧត្តម ជុំ កុសល** | រដ្ឋលេខាធិការ នៃក្រសួងព័ត៌មាន | សមាជិក |
| ៩. | **លោកជំទាវ ម៉ាត់ ម៉ារ៉ា** | រដ្ឋលេខាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិកា |
| ១០. | **លោកជំទាវ សួស រដ្ឋាវី** | អនុរដ្ឋលេខាធិការ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិកា |
| ១១. | **ឯកឧត្តម សេង សក្កដា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១២. | **ឯកឧត្តម ម៉ែន ពេជ្រសាលី** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ | សមាជិក |
| ១៣. | **លោក ជួប ណារ៉ាត់** | អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៤. | **លោកជំទាវឧត្តមសេនីយ៍ឯក ប៊ុណ្ណ សំខាន់** | អគ្គលេខាធិការនៃ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការ ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | សមាជិកា |
| ១៥. | **ឯកឧត្តមឧត្តមសេនីយ៍ឯក ខៀវ ចាន់រ៉ា** | អគ្គលេខាធិការរងនៃ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការ ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | សមាជិក |
| ១៦. | **លោកស្រី កៅ សុជីវី** | អគ្គលេខាធិការរង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិកា |
| ១៧. | **លោកជំទាវ ហួន ច័ន្ទបូរ៉ា** | នាយិកានាយកដ្ឋានទំនាក់ទំនងកាកបាទ ក្រហមកម្ពុជា នៃកាកបាទក្រហមកម្ពុជា | សមាជិកា |

១៨. **ឯកឧត្តមបណ្ឌិត ស៊ីន សេងហុក** ប្រធាននាយកដ្ឋាននីតិកម្ម នៃក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១៩. **លោក ទៀវ ទិត្យាភោមល** ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

២០. **លោក គី សុខគីម** អនុប្រធាននាយកដ្ឋានគោលនយោបាយ ម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ នៃអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

២១. **លោកវេជ្ជបណ្ឌិតសាស្ត្រាចារ្យ គឹម សាឌួន** អនុប្រធាននាយកដ្ឋាន មន្ទីរពេទ្យ នៃក្រសួងសុខាភិបាល សមាជិក

២២. **លោកវរសេនីយ៍ឯក ល៉ៅ លីន** អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរ មនុស្សនិងការពារអនីតិជននៃអគ្គស្នងការដ្ឋាន នគរបាលជាតិ នៃក្រសួងមហាផ្ទៃ សមាជិក

២៣. គ្រប់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត សមាជិក

២៤. **លោក មុំ សុខចារ** នាយកអង្គការ ជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី សមាជិក

២៥. **លោក សុខ សំបូរ** អ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិនៃ អង្គការអន្តរជាតិខាងការងារ សមាជិក

២៦. **លោក ឯក សំអុល** មន្ត្រីគម្រោងនៃ អង្គការទេសន្តរប្រវេសន៍អន្តរជាតិ សមាជិក

២៧. **លោកស្រី ឃុន សោភា** មន្ត្រីកម្មវិធីថ្នាក់ជាតិនៃ អង្គការ UNWOMEN សមាជិកា

២៨. **លោកជំទាវឧកញ៉ា អ៊ឹង ស៊ាងរិទ្ធី** ប្រធានសមាគម ទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា សមាជិកា

២៩. **លោក អន ម៉ិនហាក់** ប្រធានសមាគម ទីភ្នាក់ងារហត្ថពលកម្មកម្ពុជា សមាជិក

**ប្រការ២ ._**

ក្រុមការងារនេះ មានតួនាទី និងភារកិច្ចដូចតទៅ៖

- ជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរ មនុស្ស និងការជួយជនរងគ្រោះដោយសារការជួញដូរ
- ជំរុញការចូលរួម និងសហប្រតិបត្តិការរបស់រដ្ឋភាគី ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងផ្នែកឯកជន ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាពិសេស កុមារ និងស្ត្រី ការកេងប្រវ័ញ្ចផ្លូវភេទនិងកម្លាំងពលកម្ម និងពលកម្មដោយបង្ខំ រវាងប្រទេសទាំងពីរ
- សិក្សាលទ្ធភាព និងលើកវិធានការគាំពារសង្គម កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ សេវារកការងារឱ្យធ្វើ និងការថែទាំសុខភាពដល់ប្រជាជន ដែលងាយរងគ្រោះដោយសារការជួញដូរ
- លើកកម្ពស់ការយល់ដឹងអំពីការធ្វើទេសន្តរប្រវេសន៍ដោយសុវត្ថិភាព និងហានិភ័យផ្សេងៗដែលអាច កើតឡើងពីការធ្វើទេសន្តរប្រវេសន៍ដោយប្រថុយប្រថាន

- សម្របសម្រួលការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ ជាពិសេសកុមារ និងស្ត្រី ដោយសារការជួញដូរប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពទៅក្នុងគ្រួសារ និងសហគមន៍
- ជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីផ្នែកច្បាប់ ក្នុងការបង្ក្រាប និងផ្ដន្ទាទោសចំពោះបទល្មើសជួញដូរមនុស្សឆ្លងដែន ដោយអនុលោមទៅតាមសន្ធិសញ្ញាស្ដីពីបត្យាប័នរវាងប្រទេសកម្ពុជា និងប្រទេសថៃ និងសន្ធិសញ្ញាស្ដីពីជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌ
- រៀបចំផែនការយុទ្ធសាស្ត្រ សកម្មភាព និងលិខិតបទដ្ឋានផ្សេងៗ សំដៅធានាប្រសិទ្ធភាពនៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា
- រៀបចំកិច្ចប្រជុំក្រុមការងារចម្រុះទ្វេភាគីតាមការចាំបាច់ និងធ្វើរបាយការណ៍អំពីលទ្ធផលកិច្ចប្រជុំ និងការងារ ប្រចាំឆ្នាំជូនរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ឱ្យ។

**ប្រការ៣ .-**

អនុប្រធាន និងសមាជិកក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានណាម្នាក់ដើម្បីដឹកនាំជំនួស។

**ប្រការ៤ .-**

ក្រុមការងារនេះមានសិទ្ធិប្រើរូបសញ្ញា និងត្រារបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ